


# សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី និងសិទ្ធិក្នុងការនិយាយជាមួយមេធាវី

## និយមន័យ

សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តីមានចែងអំពីលក្ខណៈវិនិច្ឆ័យដែលតម្រូវ ដើម្បីធានាថាជនជាប់ចោទមានពេលវេលា និងមធ្យោបាយអាចការពារខ្លួនបានត្រឹមត្រូវ។ សិទ្ធិនេះអនុវត្តនៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធីផ្លូវច្បាប់ទាំងអស់ និងចំពោះការចោទប្រកាន់រឿងព្រហ្មទណ្ឌទាំងអស់ដោយមិនគិតអំពីភាពធ្ងន់ធ្ងរនោះទេ។





ពេលវេលាគ្រប់គ្រាន់៖ រយៈពេលដែល "គ្រប់គ្រាន់" អាស្រ័យទៅលើកាលៈទេសៈនៃសំណុំរឿងនីមួយៗ។ លក្ខខណ្ឌតម្រូវនៃ "ពេលវេលាគ្រប់គ្រាន់" គឺដើម្បីធានាថាជនជាប់ចោទអាចរៀបចំបានត្រឹមត្រូវក្នុងការពារក្តីទល់នឹងភស្តុតាងរបស់អយ្យការ ការស៊ើបអង្កេត និងការបង្ហាញសាក្សីការពារក្តី។



មធ្យោបាយគ្រប់គ្រាន់៖ មធ្យោបាយចាំបាច់ដែលមេធាវីការពារក្តីត្រូវការរួមមានការទទួលបានឯកសារសំណុំរឿង និងភស្តុតាង ការទទួលបានឯកសារវត្ថុតាងទាំងអស់ដែលតំណាងអយ្យការគ្រោងនឹងបង្ហាញនៅក្នុងតុលាការ ឬដែលជាភស្តុតាងដោះបន្ទុក និងការទទួលបានសេចក្តីសម្រេចរបស់សាលាដំបូងដោយមានសំអាងហេតុត្រឹមត្រូវ ជាលាយល័ក្ខអក្សរ និងឯកសារចម្លងអំពីការជំនុំជម្រះនៅដំណាក់កាលបណ្តឹងឧទ្ធរណ៍។

ជនជាប់ចោទក៏ត្រូវមានពេលវេលាក្នុងការនិយាយជាមួយមេធាវីដែលខ្លួនបានជ្រើសរើស និងទទួលបានការអនុញ្ញាតឱ្យមានមេធាវីការពារក្តីភ្លាមៗ។ សិទ្ធិនេះត្រូវបានផ្តល់ជូនចំពោះជនជាប់ចោទទាំងអស់ ប៉ុន្តែកាន់តែមានសារសំខាន់នៅពេលដែលជនជាប់ចោទត្រូវបានឃុំខ្លួន ឬជាប់ពន្ធនាគារ។ ជនជាប់ចោទស្ថិតនៅក្រោមការឃុំខ្លួន ត្រូវតែអាចប្រាស្រ័យទាក់ទងជាមួយមេធាវីរបស់ខ្លួនដោយសម្ងាត់ និងគ្មានការរឹតត្បិតអំណាច ឬការជ្រៀតជ្រែកហួសហេតុ។



## ក្របខ័ណ្ឌច្បាប់

### ច្បាប់អន្តរជាតិ

សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី និងសិទ្ធិនិយាយជាមួយមេធាវីត្រូវបានការពារយ៉ាងច្បាស់ដោយមាត្រា ១៤ (៣)(ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលបានចែង "ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំ ការពារក្តី និងការប្រាស្រ័យទាក់ទងជាមួយមេធាវីដែលខ្លួនបានជ្រើសរើស"។



# ច្បាប់ជាតិ




សិទ្ធិទាំងនេះក៏បានការពារដោយមាត្រា ៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែង "ប្រសិនបើជនជាប់ចោទសុំរយៈពេល ឬប្រសិនបើតុលាការយល់ឃើញថា រឿងក្ដីនោះមិនទាន់អាចជំនុំជម្រះភ្លាមៗបានទេនោះ សំណុំរឿងត្រូវលើកទៅសវនាការពេលក្រោយ"។ ហើយសិទ្ធិនេះក៏បានបញ្ញត្តិនៅក្នុងមាត្រាមួយចំនួននៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាដូចជាមាត្រា ១៤៥, ២៥៩, ៣១៩, និងមាត្រា ២៩ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន។

# សារសំខាន់

សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្ដី និងសិទ្ធិនិយាយជាមួយមេធាវី គឺពិតជាមានសារសំខាន់ណាស់ក្នុងការធានានូវការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការអនុវត្តគោលការណ៍ជាមូលដ្ឋាននៃសិទ្ធិស្មើភាពគ្នា ដែលអនុញ្ញាតឱ្យទាំងអយ្យការ និងភាគីជនជាប់ចោទមានឱកាសស្មើគ្នាក្នុងការរៀបចំ និងបង្ហាញសំណុំរឿងរបស់ពួកគេ។

ការធានាឱ្យមានការជំនុំជម្រះដោយយុត្តិធម៌មានវិសាលភាពហួសពីនៅក្នុងបន្ទប់សវនាការ។ ការមិនអនុញ្ញាតឱ្យជនជាប់ចោទមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្ដី អាចមានហានិភ័យដែលនាំឱ្យមានការផ្ដន្ទាទោសខុស និងការជម្រះក្ដីដោយភាន់ច្រឡំ។

# ដែនកំណត់

សិទ្ធិរបស់ជនជាប់ចោទក្នុងការមានមធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការពារក្ដី ដែលផ្ដល់សិទ្ធិឱ្យជនជាប់ចោទទទួលបានឯកសារភស្ដុតាងទាំងអស់ ដែលអយ្យការគ្រោងនឹងបង្ហាញនៅក្នុងតុលាការ ឬដែលជាភស្ដុតាងដោះបន្ទុក គឺមិនមែនជាសិទ្ធិដាច់ខាត ហើយដូច្នេះអាចរឹតត្បិតនៅក្នុងករណីពិសេស។

នៅក្នុងកាលៈទេសៈលើកលែង តុលាការអាចអនុញ្ញាតឱ្យអយ្យការរក្សាទុកមិនបង្ហាញឯកសារមួយចំនួនដល់មេធាវីការពារក្ដី។ ទោះជាយ៉ាងណាក៏ដោយ ការមិនបង្ហាញនេះ ត្រូវមានគោលបំណងស្របច្បាប់ (ឧ. ដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់បុគ្គលផ្សេងទៀត ឬដើម្បីការពារសន្តិសុខជាតិ ឬការពារផលប្រយោជន៍សាធារណៈសំខាន់ៗ) និងភាពចាំបាច់យ៉ាងតឹងរ៉ឹង និងមានសមាមាត្រស្របតាមគោលបំណងស្របច្បាប់។ ការរឹតត្បិតណាមួយលើសិទ្ធិរបស់ភាគីជនជាប់ចោទក្នុងការទទួលបានភស្ដុតាង ត្រូវមានការសម្រេចដោយតុលាការ និងមិនត្រូវធ្វើឱ្យប៉ះពាល់ដល់គោលការណ៍ស្មើភាពគ្នា និងភាពយុត្តិធម៌នៃសវនាការនោះទេ។

សិទ្ធិនិយាយជាមួយមេធាវីរបស់ជនស្ថិតនៅក្រោមការឃុំខ្លួន ឬជាប់ពន្ធនាគារអាចត្រូវបានរឹតត្បិត ឬពន្យារនៅក្នុងកាលៈទេសៈលើកលែង។ កាលៈទេសៈទាំងនេះត្រូវតែមានបញ្ញាក់ដោយច្បាប់ ឬបទប្បញ្ញត្តិស្របច្បាប់ និងចាត់ទុកថាមិនអាចខ្វះបាន ដោយស្ថាប័នតុលាការ ឬអាជ្ញាធរផ្សេងទៀត ដើម្បីរក្សាសន្តិសុខ និងសណ្ដាប់ធ្នាប់ល្អ។ មិនថានៅក្នុងកាលៈទេសៈណាក៏ដោយ ការប្រាស្រ័យទាក់ទងរវាងជនជាបចោទ និងមេធាវីរបស់ពួកគេមិនអាចបដិសេធបានទេ ចំពោះបុគ្គលដែលត្រូវបានឃុំខ្លួន ឬជាប់ពន្ធនាគារមិនឱ្យពីរបីថ្ងៃឡើយ។

ខែកញ្ញា ឆ្នាំ២០២២

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

Sweden
Sverige

People Change the World
Diakonia

CC BY NC SA